ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
**-លេខ: ៨១ "អ"**
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១
-សំណុំរឿងព្រហ្មទណ្ឌលេខ ២៣២៥
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ ១៥៧០
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខ ៣៧៣៩
ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ០៨ : ០០ នាទីព្រឹក នៅសាលសវនាការទី ១ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៣២៥ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] **ផារ័ត្ន** ភេទប្រុស អាយុ២៤ឆ្នាំ (កើតឆ្នាំ១៩៩៦) សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួន ស្នាក់នៅផ្ទះមិនចាំលេខ ផ្លូវលំ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ណារី "ស្លាប់" ម្តាយឈ្មោះ [redacted] សុខុន "រស់" ប្រពន្ធឈ្មោះ [redacted] ស្រីនី មានកូនចំនួន ០១ នាក់ ជា-នីតិជន ទោសពីមុន-គ្មាន ។ (ក្នុងឃុំ)

**-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤០៧៤ "ក១"ដ.ឃ.ដ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ (PJ) ។**

២.ឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ១៩ឆ្នាំ (កើតឆ្នាំ២០០១) សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល ផ្លូវបេតុង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ ថា "រស់" ម្តាយឈ្មោះ [redacted] គីម "រស់" នៅលីវ ជា-នីតិជន ទោសពីមុន-គ្មាន ។ (ក្នុងឃុំ)

**-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤០៧៣ "ក១"ដ.ឃ.ដ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ (PJ) ។**

ជាប់ចោទពីបទ **ជួញដូរប្រព្រឹត្តច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចវត្តតាំងក្រសាំង ភូមិចំការឪឡឹក សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែកុម្ភៈ ឆ្នាំ២០២០



Scanned with CamScanner

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ផារ័ត្ន បានឆ្លើយថា ៖ ខ្លួនបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ម៉ាទឹកកក) បានរយៈពេលប្រហែលជាងមួយខែមកហើយរហូតមកដល់បច្ចុប្បន្ន ដោយទិញពីឈ្មោះ យ៉ា ភេទប្រុស ជាច្រើនលើក ក្នុងមួយលើកៗចាប់ពីកន្លះជ្រុងដល់មួយជ្រុង (កន្លះជ្រុងតម្លៃ ហុកសិបម៉ឺន) រៀល ។ ពេលខ្លួនទិញថ្នាំញៀនបានហើយ បានយកមកវែកលក់ក្នុងមួយកូនកញ្ចប់តម្លៃ ២ ម៉ឺនរៀល ដល់ ៤ ម៉ឺនរៀល (រាល់ពេលលក់អស់ខ្លួនចំណេញបាន១០ម៉ឺនរៀល និងសល់គ្រឿងញៀនខ្លះទុកប្រើខ្លួនឯង) ។ លុះនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជាង៣រសៀល ខ្លួនបានលក់គ្រឿងញៀនឱ្យបុរសម្នាក់ ចំនួន០១កញ្ចប់តូច តម្លៃប្រាំម៉ឺនរៀល នៅចំណុចបរិវេណវត្តតាំងក្រសាំងខាងជើង មួយសន្ទុះក្រោយមកក៏ត្រូវសមត្ថកិច្ចចុះបង្ក្រាប និងដកហូតវត្ថុតាងគ្រឿងញៀនចំនួន ០៣ កញ្ចប់តូច, ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ០១ និងឧបករណ៍ពាក់ព័ន្ធជាមួយបទល្មើសគ្រឿងញៀនមួយចំនួនទៀត ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល៣ឆ្នាំមកហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ចិត្រា បានឆ្លើយថា ៖ ខ្លួនបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ម៉ាទឹកកក) បានប្រហែលកន្លះខែមកហើយ រហូតមកដល់បច្ចុប្បន្ន ។ ចំពោះគ្រឿងញៀនដែលខ្លួនធ្វើសកម្មភាពជួញដូរនោះគឺឈ្មោះ [redacted] ផារ័ត្ន បានប្រើឱ្យខ្លួនយកគ្រឿងញៀនទៅឱ្យម៉ូយរបស់គាត់ជាច្រើនលើក ក្នុងមួយលើកៗចំនួន០១កូនកញ្ចប់តូច តម្លៃ២ម៉ឺនរៀល ហើយឈ្មោះ [redacted] ផារ័ត្ន បានឱ្យថ្លៃឈ្នួលមកខ្លួន ដោយបានទិញបាយ ទឹក ទឹកក្រូច ឱ្យហូប ព្រោះខ្លួនមករស់នៅជាមួយគាត់បានរយៈពេលប្រហែលកន្លះខែមកហើយ ។ លុះដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល៣រសៀល ខ្លួន និងឈ្មោះ [redacted] ផារ័ត្ន ទៅចំណុចវត្តតាំងក្រសាំងខាងជើង ហើយបានធ្វើសកម្មភាពជួញដូរគ្រឿងញៀន ក៏ត្រូវសមត្ថកិច្ចចុះបង្ក្រាប និងដកហូតវត្ថុតាងគ្រឿងញៀនមួយចំនួន និងសម្ភារៈពាក់ព័ន្ធជាមួយបទល្មើសគ្រឿងញៀនមួយចំនួន ។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល២ឆ្នាំមកហើយ ។

-តាមអំណានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២៥១៦៤/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា ៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬ ម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៨០,០៧% នៃទម្ងន់សរុប, វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការតំណាងអយ្យការឃើញថា កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៦ និង ០០ នាទី ស្ថិតនៅចំណុចវត្តតាំងក្រសាំង ភូមិចំការឪឡឹក សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន ពិតជាបានចុះបង្ក្រាបករណីជាក់ស្តែងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយបានចាប់ឃាត់ជនជាប់ចោទឈ្មោះ [redacted] ផារ័ត្ន ភេទប្រុស អាយុ២៤ឆ្នាំ និងឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ១៩ឆ្នាំ ដែលធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀនជាច្រើនដង កាលពីខែកុម្ភៈ ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ប្រាកដមែន ហើយសមត្ថកិច្ចក៏បានធ្វើតេស្តទឹកនោមលើជនជាប់ចោទដើម្បីស្វែងរកសារធាតុញៀន ជាលទ្ធផលបង្ហាញថាវិជ្ជមាន ។ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ធារ័ត្ន និងឈ្មោះ [redacted] ចិត្រា បានឆ្លើយប្រហាក់ប្រហែលគ្នាថា ៖ ពួកខ្លួនធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន (ម៉ាទឹកកក) អស់រយៈពេលប្រហែលជាងមួយខែមកហើយ រហូតមកដល់ថ្ងៃកើតហេតុ ដោយទិញយកមករំលែកលក់ក្នុងមួយកូនកញ្ចប់តម្លៃ ២ ម៉ឺនរៀល ដល់៤ម៉ឺនរៀល ។ លុះដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ វេលាម៉ោងប្រហែល៣រសៀល ពួកខ្លួនបានធ្វើសកម្មភាពជួញដូរគ្រឿងញៀននៅចំណុចវត្តតាំងក្រសាំងខាងជើង ក៏ត្រូវសមត្ថកិច្ចចុះបង្ក្រាប និងដកហូតវត្ថុតាងគ្រឿងញៀនមួយចំនួន និងសម្ភារៈពាក់ព័ន្ធជាមួយបទល្មើសគ្រឿងញៀនមួយចំនួន ។ ពួកខ្លួនចេះប្រើប្រាស់គ្រឿងញៀន រយៈពេលប្រហែល ២ ឆ្នាំមកហើយ ។

-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២៥១៦៤/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា ៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬ ម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៨០,០៧% នៃទម្ងន់សរុប, វាស្ថិតក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

-តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋានរាជធានីភ្នំពេញ ជាលទ្ធផលបង្ហាញថា មានវត្តមានសារធាតុញៀន ប្រភេទមេតំហ្វេតាមីនក្នុងទឹកនោមរបស់ជនជាប់ចោទឈ្មោះ [redacted] ធារ័ត្ន និងឈ្មោះ [redacted] ចិត្រា ដែលបញ្ជាក់ថាជនជាប់ចោទពិតជាបាន ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

-ចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងផ្សេងៗ បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ធារ័ត្ន និងឈ្មោះ [redacted] ចិត្រា ពិតជាបានប្រព្រឹត្តអំពើ ជួញដូរប្រព្រឹត្តច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចវត្តតាំងក្រសាំង ភូមិចំការឪឡឹក សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែកុម្ភៈ ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន ។

-អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរ ជាពិសេសប្រព័ន្ធសរសៃប្រសាទ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គម សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ជាអំពើល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ជនជាប់ចោទជានីតិជន និងជាជនដែលមាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណាមួយ ដែលនាំឱ្យមានមន្ទិលសង្ស័យថាជននេះមានវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសទេ ។ ជននេះមានការពិចារណាយល់ដឹងអំពីផលវិបាកកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ធារ័ត្ន ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរប្រព្រឹត្តច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចវត្តតាំងក្រសាំង ភូមិចំការឪឡឹក សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែកុម្ភៈ ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ពីបទ ជួញដូរប្រព្រឹត្តច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចវត្ត តាំងក្រសាំង ភូមិចំការឪឡឹក សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីខែកុម្ភៈ ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ទី៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យកដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១០៧៩ រ.វ.ត ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញ រួមមាន ៖

១-ម្សៅក្រាមសថ្លាទម្ងន់ ១,៥៤ (មួយកណ្តាក់សញ្ញាហាសិបបួន) ក្រាម ។

២-ទូរស័ព្ទដៃ ម៉ា NOKIA ចុចពិល (មិនដំណើរការ) ចំនួន ០២ គ្រឿង ។

៣-ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ចំនួន ០១ ។

៤-ដាវដែក ចំនួន០១ និងកាំបិត ចំនួន ០១ ។

**ត្រូវរឹបអូស ។**

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធារ័ត្ន និងឈ្មោះ [redacted] ចិត្រា និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ។

បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner